# I. ទីស្តីការគណៈរដ្ឋមន្ត្រី

## អនុក្រឹត្យ

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ១៩៩៤

## អនុក្រឹត្យលេខ ២០អនក្រ ស្តីពី

## ការបង្កើតអង្គភាពបង្ការ និងពន្លត់អគ្គីភ័យ

* * *

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុវរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- ផ្អែកតាមស្មារតីប្រជុំគណៈរដ្ឋមន្ត្រីពេញអង្គ នាថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៤

## សំរេច

**មាត្រា ១** ៖ បង្កើតអង្គភាពបង្ការ និង ពន្លត់អគ្គីភ័យមួយ ស្ថិតក្រោមការគ្រប់គ្រង របស់រាជធានីភ្នំពេញ និង ខេត្ត- ក្រុង

**មាត្រា ២** : អង្គភាពបង្ការ និង ពន្លត់អគ្គីភ័យ មានភារកិច្ច និង ភារកិច្ចដូចតទៅ ÷

- បង្ការ និងទប់ស្កាត់គ្រោះថ្នាក់ដោយអគ្គីភ័យ ដើម្បីការពារអាយុជីវិត ទ្រព្យសម្បត្តិជាតិ និងទ្រព្យសម្បត្តិរបស់ប្រជារាស្ត្រ ។
- រៀបចំបទបញ្ជាអោយមានប្រសិទ្ធិភាពខ្ពស់ ស្តីពីការងារបង្ការ និង ពន្លត់អគ្គីភ័យ ។
- អប់រំបុគ្គលិក អោយអនុវត្តតាមបទបញ្ជា ស្តីពីការងារបង្ការ និង ពន្លត់អគ្គីភ័យរបស់អង្គភាព ។

- រៀបចំប្រព័ន្ធបង្ការ និង ពន្លត់អគ្គីភ័យនៅគ្រប់មូលដ្ឋាន ក្រោមឱវាទ ។
- បណ្តុះបណ្តាលមុខជំនាញបច្ចេកទេស ដល់ភ្នាក់ងារបង្ការ និង ពន្លត់អគ្គីភ័យ ។
- ផ្សព្វផ្សាយ និង ណែនាំប្រជាពលរដ្ឋ អំពីវិធីបង្ការ និង ពន្លត់អគ្គីភ័យ ។
- ចាត់គ្រប់វិធានការបន្ទាន់ ដើម្បីប្រយុទ្ធទល់នឹងអគ្គីភ័យ ដែលកើតមាន ។
- ជួយសង្គ្រោះជនរងគ្រោះថ្នាក់ដោយអគ្គីភ័យ ។

**មាត្រា ៣ :** ត្រូវបានផ្ទេរក្របខ័ណ្ឌបុគ្គលិក ឧបករណ៍សំភារៈ និង មធ្យោបាយសំរាប់បំពេញការងារបង្ការ និង ពន្លត់អគ្គីភ័យ ពីក្រសួងមហាផ្ទៃ មកអោយរាជធានីភ្នំពេញគ្រប់គ្រង ។

**មាត្រា ៤ :** បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាលរាជធានីភ្នំពេញ និង អស់លោកអភិបាលគ្រប់ខេត្ត ក្រុង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខាតទៅ ។

**នាយករដ្ឋមន្ត្រីទី១**
ព្រះហស្ថលេខានិងត្រា
**នរោត្តម រណឫទ្ធិ**

**នាយករដ្ឋមន្ត្រីទី២**
ហត្ថលេខា និងត្រា
**ហ៊ុន សែន**